ក្រុមសៀវភៅការរុករកឃើញ®

# តើព្រះទាំងអស់ សុទ្ធតែដូចគ្នាឬ?

## ការពិភាក្សាអំពី សេចក្តីពិត ចំណេះដឹង និងទស្សនៈ



និពន្ធដោយ : Jose Philip



# បុព្វកថា

**តើសាសនាទាំងអស់** សុទ្ធតែដឹកនាំមនុស្ស ឆ្ពោះទៅរកព្រះតែមួយមែនទេ? តើព្រះទាំងអស់សុទ្ធតែដូចគ្នាឬ? ហេតុអ្វីបានជាជំនឿរបស់គ្រីស្ទបរិស័ទមានលក្ខណៈខុសពីគេយ៉ាងនេះ? តើសេចក្ដីពិតមានទំនាក់ទំនងជាមួយគ្នាតើមែនទេ? ហេតុអ្វីបានជាយើងមិនឆាប់យល់ស្របមតិរបស់គេ ដើម្បីឲ្យឆាប់ចប់រឿង?

អ្នកប្រហែលជាធ្លាប់មានសំណួរដូចនេះផងដែរ នៅពេលដែលនរណាម្នាក់ព្យាយាមជជែកជាមួយអ្នក អំពីព្រះ ឬសាសនា។ ហើយសំណួរទាំងអស់សុទ្ធតែជាសំណួរល្អ!

លោកចូស ហ្វីលីព(Jose Philip) បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ដើម្បីធ្វើការបម្រើព្រះ ជាគ្រូអធិប្បាយ គ្រូបង្រៀន និងអ្នកការពារជំនឿគ្រីស្ទបរិស័ទ។ គាត់បានលើកយកសំណួរទាំងនេះ មកបកស្រាយ យ៉ាងសមហេតុផល។ គាត់បានធ្វើការបកស្រាយ តាមបែបទស្សនវិជ្ជា ជាជាងតាមរបៀបសាសនា ដោយធ្វើការប្រៀបធៀបរវាង ភាពខុសប្លែកពីគេ ភាពជាប់ទាក់ទង និងសេចក្ដីពិតដាច់ខាត និងលើកឡើងអំពីមូលដ្ឋានគ្រឹះនៃចំណេះដឹង ដែលជាបញ្ហាដ៏សំខាន់ ដែលជះឥទ្ធិពលមកលើចម្លើយរបស់សំណួរ ដែលបានចោទឡើងថា “តើព្រះទាំងអស់សុទ្ធតែដូចគ្នាមែនទេ?”



*យើងខ្ញុំមិនមែនកំពុងតែបញ្ចុះបញ្ចូលអ្នកឲ្យផ្លាស់ប្ដូរជំនឿភ្លាមៗនោះទេ។*

អ្នកប្រហែលជាយល់ថា សៀវភៅនេះមានលក្ខណៈចម្លែកបន្តិច ដោយវាមិនបាននិយាយតាមលំដាប់លំដោយ ហើយជំពូកនីមួយៗហាក់ដូចជាមិនមានទំនាក់ទំនងដ៏រលូន ជាមួយគ្នា។ លោកចូសហាក់ដូចជាកំពុងតែលោតពីប្រធានបទមួយចូលប្រធានបទមួយទៀត។ ប៉ុន្តែ គាត់ចាំបាច់ត្រូវធ្វើដូចនេះ។ ព្រោះថា ពេលណាយើងយកប្រធានបទដ៏ស្មុគស្មាញមកនិយាយ យើងចាំបាច់ត្រូវចំណាយពេលបង្វិលប្រធានបទនោះ ចុះឡើង ដើម្បីពិនិត្យមើលវា តាមជ្រុងផ្សេងៗគ្នា។ ដូចនេះ លោកចូសនឹងចំណាយពេលពិនិត្យមើលជ្រុងនីមួយៗ នៃការជជែកដេញដោល ដែលធំជាង អំពីសេចក្ដីពិត ដោយពិនិត្យមើលមូលដ្ឋានគ្រឹះនៃចំណេះដឹង ជំនឿ និងទស្សនៈ ហើយសង្ឃឹមថា នឹងបានយល់កាន់តែច្បាស់ អំពីបញ្ហាទាំងមូល។

ជាងនេះទៅទៀត យើងខ្ញុំមិនមែនកំពុងតែបញ្ចុះបញ្ចូលអ្នកឲ្យផ្លាស់ប្តូរជំនឿភ្លាមៗនោះទេ។ ផ្ទុយទៅវិញ លោកចូសសង្ឃឹមថា នឹងបានលើកទឹកចិត្តអ្នកឲ្យមានការរិះគិតបន្ថែមទៀត អំពីអ្វីដែលអ្នកជឿ និងគិត ហើយចោទសួរអំពីមូលដ្ឋានគ្រឹះនៃជំនឿរបស់អ្នក ដូចដែលអ្នកបានចោទសួរអំពីជំនឿរបស់គ្រីស្ទបរិស័ទផងដែរ។

**EDITOR:** Asia Pacific Content Development Team
**COVER DESIGN:** Mary Tham
**COVER IMAGE:** shutterstock.com
**INTERIOR DESIGN:** Grace Goh
**INTERIOR IMAGES:** (pp. 1, 7, 11, 15, 19, 23, 27, 33, 37, 45) shutterstock.com

The themes in "Are All Gods the Same?" can also be found in *Since You Asked*, a new book by Jose Philip (not published yet at the time of printing of this booklet)

Unless otherwise indicated, all Scripture quotations are taken from the Holy Bible, New Living Translation, copyright © 1996, 2004, 2015 by Tyndale House Foundation. Used by permission of Tyndale House Publishers, Inc., Carol Stream, Illinois 60188. All rights reserved.

All rights reserved
© 2019 Our Daily Bread Ministries
Printed in Singapore

? ? ? ? ? ? ?

*សេចក្តីផ្តើម*

តើព្រះទាំងអស់សុទ្ធតែដូចគ្នាឬ? ..................................8

*ទី១*

ហេតុអ្វីយើងមិនយល់ស្របគំនិតគេ ដើម្បីឲ្យឆាប់ចប់រឿង?...12

*ទី២*

តើសេចក្តីពិតអាស្រ័យទៅលើទស្សនៈបុគ្គលឬ?................16

*ទី៣*

តើសាសនាទាំងអស់សុទ្ធតែបង្រៀនដូចគ្នាឬ? ...................20

*ទី៤*

ហេតុអ្វីសេចក្តីពិតមានភាពដាច់ខាត? ............................24

*ទី៥*

ហេតុអ្វីបានជាយើងជឿ? ..........................................28

*ទី៦*

តើយើងអាចស្វែងរកសេចក្តីពិត ដោយរបៀបណា?...........34

*ទី៧*

តើយើងអាចរកឃើញព្រះ ដោយរបៀបណា?..................38

*ទី៨*

តើយើងអាចរកឃើញព្រះ ដោយរបៀបណា? .................46



*សេចក្តីផ្តើម*

## តើព្រះនាំងអស់សុទ្ធតែដូចគ្នាឬ?

ការវែកញែក អំពីសេចក្តីពិត ចំណេះដឹង និងទស្សនៈ

**សព្វថ្ងៃនេះ មនុស្សជាច្រើនមិនយល់ស្រប** ចំពោះទស្សនៈដែលថា សេចក្តីពិតមិនអាស្រ័យទៅលើការគិតរបស់មនុស្ស។ តើមែនទេ? ពួកគេចង់មានសេរីភាព នៅក្នុងការសម្រេចដោយខ្លួនឯងថា អ្វីពិត ឬមិនពិត។ ទន្ទឹមនឹងនោះ ជាញឹកញាប់ យើងច្រើនតែទាមទាឲ្យអ្នកដទៃមានភាពពិតត្រង់ចំពោះយើង។ ការនេះបាននាំឲ្យមានសំណួរមួយ ដែលយើងពិបាកឆ្លើយ។ តើធ្វើដូចម្តេចឲ្យយើងអាចរំពឹងឲ្យនរណាម្នាក់មានភាពពិតត្រង់ចំពោះយើង ពេលដែលកូនស្រីរបស់ខ្ញុំ ដែលមានអាយុ១២ឆ្នាំ បានអះអាងថា “ការនិយាយប្រឌិត” មានភាពគួរឲ្យចាប់អារម្មណ៍ ជាងការនិយាយអ្វីដែលពិត?

មិនមែនមានតែក្មេងៗទេ ដែលចូលចិត្តនិយាយប្រឌិត ឬសន្មត់ថា រឿងណាមួយជារឿងពិត។ យើងច្រើនតែឲ្យតម្លៃទៅលើអារម្មណ៍របស់យើង ឬឲ្យតម្លៃ

ទៅលើអ្វីដែលអាចធ្វើទៅរួច សម្រាប់យើង ជាជាងឲ្យតម្លៃទៅលើអ្វីដែលជាការពិត។ ជាញឹកញាប់ គេនិយាយប្រាប់យើងថា រឿងមួយពិតឬអត់ គឺអាស្រ័យទៅលើការគិតរបស់យើង ហើយអ្នកដែលប្រកាន់ខ្ជាប់នូវជំនឿ ឬសាសនាណាមួយយ៉ាងរឹងមាំ មានការពិបាក នៅក្នុងការទទួលយកទស្សនៈបែបនេះ។

ខ្ញុំបានទទួលការអញ្ជើញជាញឹកញាប់ ឲ្យទៅចែកចាយ អំពីប្រធានបទផ្សេងៗ។ មានពេលមួយនោះ គេបានឲ្យខ្ញុំចែកចាយ ដោយផ្អែកទៅលើសំណួរ ដែលសួរថា “តើសាសនាទាំងអស់សុទ្ធតែនាំផ្លូវយើង ទៅរកព្រះតែមួយឬ?” នៅក្នុងការរៀបចំគម្រោងចែកចាយ អំពីសំណួរនេះ ខ្ញុំក៏បានសម្រេចចិត្ត ធ្វើការស្ទង់មតិដ៏ឆាប់រហ័សមួយ។ នៅក្នុនោះ ខ្ញុំចង់ដឹងការពីរយ៉ាង។ តើមនុស្សពិតជាជឿថា សាសនាទាំងអស់សុទ្ធតែដូចគ្នាមែនទេ? បើសិនជាគេជឿដូចនេះមែន តើមូលហេតុអ្វី?

ដូចនេះ រៀងរាល់ពេលដែលខ្ញុំបានទៅហាងកាហ្វេ ឬបណ្ណាគា ខ្ញុំតែងតែដកកំព្យូទ័រយួរដៃរបស់ខ្ញុំចេញមក ហើយវាយពាក្យថា “ហេតុអ្វីគេជឿថា សាសនាទាំងអស់សុទ្ធតែនាំមនុស្សទៅរកព្រះតែមួយ?” ហើយខ្ញុំក៏បានពង្រីកអក្សរនៅលើអេក្រង់កំព្យូទ័ររបស់ខ្ញុំ ឲ្យមានទំហំធំល្មម នឹងអាចឲ្យមនុស្សដែលអង្គុយនៅក្បែរខ្ញុំអាចចាប់អារម្មណ៍។

នេះជាការពិសោធន៍ដែលអស្ចារ្យណាស់ ហើយជាលទ្ធផល ការនេះក៏បាននាំឲ្យខ្ញុំមានការសន្ទនាដ៏គួរឲ្យចាប់អារម្មណ៍។ ជាញឹកញាប់ មានអ្នកខ្លះបានឃើញពាក្យនៅលើអេក្រង់កំព្យូទ័រខ្ញុំ ហើយមិនយូរប៉ុន្មាន ពួកគេក៏បានផ្អៀងខ្លួនមករកកំព្យូទ័រខ្ញុំ ហើយសួរថា “ហេតុអ្វីអ្នកមិនជឿថា សាសនាទាំងអស់នាំមនុស្សទៅរកព្រះ?”

ខ្ញុំក៏បានរកឃើញថា មនុស្សជាច្រើន ដែលមានជំនឿសាសនា ឬមិនជឿសោះថាព្រះមានមែន គឺសុទ្ធតែទទួលស្គាល់ថា សាសនាទាំងអស់សុទ្ធតែដូចគ្នា ទោះពួកគេមិនសូវយល់ច្បាស់ អំពីការអះអាង ឬការបង្រៀនរបស់សាសនាទាំងនោះក៏ដោយ។



*មនុស្សយើងចូលចិត្តសម្រេចចិត្តជឿដោយខ្លួនឯងថា ថាសេចក្តីពិតជាអ្វី ព្រោះពួកគេជឿថា សេចក្តីពិតមានការផ្តេកផ្តួលតាមបុគ្គលម្នាក់ៗ។*

ខ្ញុំមានការចាប់អារម្មណ៍ខ្លាំងណាស់ ពេលដែលខ្ញុំបានដឹងថា អ្នកទាំងនេះ ភាគច្រើនជឿថា ខ្លួនមានសិទ្ធិនៅក្នុងការគិតឃើញយ៉ាងដូចម្តេចក៏បាន។ មនុស្សជាច្រើនជឿថា សិទ្ធិនៅក្នុងការបញ្ចេញមតិផ្ទាល់ខ្លួន គឺពិតជាសំខាន់ខ្លាំងណាស់ គឺប្រហែលជាសំខាន់ជាងការស្វែងរកសេចក្តីពិតទៅទៀត។

ទោះជាយ៉ាងណាក៏ដោយ វាគ្មានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលទេ។ មនុស្សយើងចូលចិត្តសម្រេចចិត្តជឿដោយខ្លួនឯងថា ថាសេចក្តីពិតជាអ្វី។ ពួកគេសម្រេចចិត្តជឿដូចនេះ បន្ទាប់ពីពួកគេជឿថា សេចក្តីពិតមានការផ្តេកផ្តួល តាមបុគ្គលម្នាក់ៗ។ ហេតុនេះហើយ ពេលណាយើងឃើញនរណាម្នាក់អះអាងថា មានតែពួកគេទេ ដែលស្គាល់សេចក្តីពិត យើងក៏បានគិតថា ពួកគេកំពុងតែខ្វះការគោរព ឬថែមទាំងមានភាពក្រអឺតក្រទមទៀតផង។ ឥឡូវនេះ សូមយើងផ្អាកមួយភ្លែតសិន ដើម្បីគិតអំពីបញ្ហានេះ ដោយសួរខ្លួនឯងថា “តើនេះជារឿងដែលទើបតែកើតមានក្នុងសម័យយើង ឬមួយមនុស្សតែងតែគិតរបៀបនេះ?” បន្ទាប់ពីយើងសួរសំណួរដូចនេះហើយ យើងប្រហែលជាឃើញមានចំណុចដែលគួរឲ្យចាប់អារម្មណ៍មួយ ក្នុងរឿងនេះ។



*ទី១*

## ហេតុអ្វីយើងមិនយល់ស្របគំនិតគេ ដើម្បីឱ្យឆាប់ចប់រឿង?

**ហេតុអ្វីយើងមិនយល់ស្របគំនិតគេ** ដើម្បីឲ្យឆាប់ចប់រឿង? នេះជាអ្វីដែលមិត្តល្អរបស់ខ្ញុំម្នាក់ ធ្លាប់និយាយ ពេលណាយើងប្រកែកគ្នាអំពីជំនឿរបស់យើង។ ហើយសំណួរនេះ ហាក់ដូចជាការឆ្លើយតប ដែលសមនឹងសំណួរដែលសួរថា តើទស្សនៈទាំងអស់ ដែលមនុស្សមាន អំពីព្រះ សុទ្ធតែត្រូវដូចគ្នាឬ? ជាការពិតណាស់ បើគេគិតថា ការអះអាងទាំងអស់ប្រហែលជាត្រូវ ឬគិតថា យើងមិនអាចដឹងថា មួយណាពិតជាត្រូវ នោះមានន័យថា គេកំពុងតែបដិសេធន៍ ចំពោះការអះអាងដ៏ជាក់លាក់ និងត្រឹមត្រូវតែមួយគត់ អំពីព្រះជានរណា ។ តើអ្នកធ្លាប់គិតដូចនេះដែរទេ។

ការយល់ស្របគំនិតគេ ដើម្បីឲ្យឆាប់ចប់រឿង គឺជាការយល់ឃើញថា សេចក្តីពិតមានការផ្តេកផ្តួលទៅលើគំនិតរបស់មនុស្សម្នាក់ៗ។ ការយល់ដឹងខ្លះៗ អំពីប្រវត្តិនៃរឿងនេះ នឹងជួយឲ្យយើងយល់ ពីមូលហេតុ ដែលគេអាចចោទសួរ អំពីការអះអាងអំពីសេចក្តីពិតដែលដាច់ខាត និងយល់ពីមូលហេតុ ដែលពួកគេផ្តេកផ្តួលទៅលើអារម្មណ៍ខ្លួនឯង ខ្លាំងជាងផ្តេកផ្តួលទៅលើសេចក្តីពិត។

ការយល់ឃើញថា "សេចក្តីពិតមានការផ្តេកផ្តួល ទៅលើការគិតរបស់មនុស្ស" គឺជាគំនិតរបស់មនុស្សសម័យថ្មី ដែលមានប្រភពមកពីយុគសម័យនៃហេតុផល ដែលហៅម្យ៉ាងទៀតថា យុគសម័យនៃភាពភ្លឺស្វាង ឬរេនេសង។ យុគសម័យនេះ បានគ្របដណ្តប់សង្គមលោកខាងលិច រហូតដល់សតវត្សរ៍ទី១៨ ដោយបាននាំមនុស្សឲ្យគិតមានហេតុផល ដែលនាំឲ្យមានការរីកចម្រើន នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងការផ្លាស់ប្តូរធំៗក្នុងសង្គម ដែលមានដូចជាបដិវត្តន៍ឧស្សាហកម្មជាដើម។ ប៉ុន្តែ យុគ្គសម័យនោះ បាននាំឲ្យមានបញ្ហាប្រឈមមួយចំនួន។

ការផ្តោតទៅលើការគិតដែលសមហេតុផល បានពង្រឹងបច្ចេកវិទ្យាឲ្យរឹងមាំ ដែលជំរុញឲ្យមនុស្សមានមហិច្ឆតាកាន់តែខ្លាំង ដល់ថ្នាក់ចង់គ្រប់គ្រងពិភពលោក ដោយមនុស្សមួយក្តាប់តូច។ បញ្ហានេះបាននាំឲ្យមានសង្គ្រាមលោក ពីរលើក ដែលទីបំផុត នាំឲ្យមានការខកចិត្តជាទូទៅ ចំពោះអំណាចក្នុងវិស័យទាំងអស់ ដែលមាននយោបាយ សង្គម សេដ្ឋកិច្ច និងសាសនា។ មនុស្សជាច្រើនក៏បានងាកបែរចេញពីការគិតមានហេតុផល ហើយក៏បានវិលត្រឡប់ថយក្រោយ ទៅរកការឲ្យតម្លៃមកលើបទពិសោធន៍ និងគំនិតផ្ទាល់ខ្លួនវិញ។



*ការយល់ឃើញថា " សេចក្តីពិតមានការផ្តេកផ្តួល ទៅលើការគិតរបស់មនុស្ស" គឺជាគំនិតរបស់មនុស្សសម័យថ្មី ដែលមានប្រភពមកពីយុគសម័យនៃហេតុផល ។*

តើរឿងនេះបានបង្រៀនយើងអ្វីខ្លះ ក្នុងសម័យនេះ? ដោយសារតែការព្រួយបារម្ភ អំពីផលវិបាក ដែល អាចបណ្តាលមកពីការគិតតាមហេតុផល មនុស្សសម័យបច្ចុប្បន្ន ក៏បានជ្រើសរើសយកទ្រឹស្តីនៃការមើលឃើញជាក់ស្តែង និងជម្រើសផ្ទាល់ខ្លួន ធ្វើជាមូលដ្ឋានគ្រឹះ

នៃការគិតរបស់ខ្លួនវិញ ពោលគឺពួកគេរើសយកអ្វីដែលអាចធ្វើទៅរួច និងអ្វីដែលគេអាចយល់បាន។

ជាញឹកញាប់ គេក៏បានកាត់បន្ថយសេចក្តីពិត ឲ្យក្លាយជាអ្វីដែលគេចង់ជ្រើសរើស ឬមិនជ្រើសរើសបានតាមចិត្ត ហើយទស្សនៈរបស់បុគ្គល ត្រូវបានគេលើកដំកើង ឲ្យធ្វើជាសេចក្តីពិតវិញ។ ការផ្លាស់ប្តូរបានកើតមាន ដោយយើងបានផ្លាស់ចេញពីការព្យាយាមស្វែងយល់ និងយល់ស្រប ចំពោះសេចក្តីពិត ចូលទៅរកការបង្កើត និងលើកដំកើងទស្សនៈផ្ទាល់ខ្លួន ធ្វើជាសេចក្តីពិត។

ការនេះបាននាំឲ្យមានការឆ្លើយតបធូន់ៗដោយសួរថា "ហេតុអ្វីអ្នកចង់លើកដំកើងសេចក្តីពិតរបស់អ្នកម្ល៉េះ? ខ្ញុំមិនដែលធ្វើអញ្ចឹងទេ"។

ទស្សនវិទូសម័យដើមបានខិតខំស្វែងយល់អំពីសេចក្តីពិត តាមសភាពដើមរបស់វា តែអ្នកប្រាជ្ញសម័យបច្ចុប្បន្ន ខ្វល់អំពីការគិតរបស់មនុស្ស ខ្លាំងជាងធ្វើការស៊ើបអង្កេត។ អ្នកប្រាជ្ញាសម័យដើមជាច្រើនទទួលស្គាល់ថា ព្រះមានមែន តែអ្នកប្រាជ្ញសម័យបច្ចុប្បន្នបដិសេធ ឬមិនខ្វល់អំពីជំនឿលើព្រះឡើយ។ ប៉ុន្តែ បើសិនជាយើងពិតជាចង់ស្វែងរកសេចក្តីពិតមែន នោះការគិតរបស់មនុស្សតែម្យ៉ាងគឺមិនគ្រប់គ្រាន់ទេ។

បើយើងមិនរៀនរស់នៅដោយសុខដុម ជាមួយអ្នកដែលមានទស្សនៈខុសពីយើងទេ នោះយើងនឹងបំផ្លាញខ្លួនឯងមិនខាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកក៏អាចដឹងថា ការយល់ស្របនឹងមតិអ្នកដទៃ ដើម្បីឲ្យឆាប់ចប់រឿង ហើយការមិនដើរចេញពីទស្សនៈផ្ទាល់ខ្លួន ដើម្បីស្វែងរកសេចក្តីពិត គឺជាទង្វើរដែលមានពេញដោយបញ្ហា។ ការប្តេជ្ញាចិត្តប្រកាន់ខ្ជាប់អ្វីដែលយើងជឿថា ជាសេចក្តីពិត គឺផ្អែក

ទៅលើការសន្និដ្ឋានថា ជំនឿនឹងធ្វើឲ្យ “សេចក្ដីពិត” របស់យើង ក្លាយជាសេចក្ដីពិត។ តើមែនឬ?



*ទី២*

# តើសេចក្ដីពិតអាស្រ័យទៅលើទស្សនៈបុគ្គលឬ?

**អ្នកប្រហែលជានៅតែឆ្ងល់ថា :** តើ “ការយល់ស្របមតិអ្នកដទៃ ដើម្បីឲ្យឆាប់ចប់រឿង” មានអ្វីខុស? តើវាមិនមែនជារឿងល្អទេឬ? ជាការពិតណាស់ វាមានចំណុចល្អដែរ ប៉ុន្តែ នៅពេលដែលយើងស្វែងរកសេចក្ដីពិត យើងមិនអាចធ្វើដូចនេះបានឡើយ។

ខ្ញុំសូមលើកយកឧទាហរណ៍មួយ សម្រាប់ពិចារណា។ មានអ្នកជំងឺម្នាក់ មានមហារីកសួត បានទៅជួបគ្រូពេទ្យមហារីកមួយក្រុម ដោយសង្ឃឹមថា នឹងបានទទួលការពិនិត្យច្បាស់លាស់ និងការព្យាបាលត្រឹមត្រូវ។ ប៉ុន្តែ គ្រូទាំងនោះមានមតិខុសគ្នា មិនអាចសម្រេចថា ត្រូវព្យាបាលគាត់ដូចម្ដេចឡើយ ដូចនេះ ពួកគេម្នាក់ៗក៏បានសម្រេចចិត្តយល់ស្រប ចំពោះមតិរបស់គ្រូពេទ្យដទៃទៀត ក្នុងក្រុម “ដើម្បីឲ្យឆាប់ចប់រឿង”។ មានពួកគេម្នាក់មិនទាំងបានទទួលស្គាល់ថា បុរស់នោះមានជំងឺអ្វីឡើយ។ ពួកគេមិនបានស្វែងរកការពិតនៃជំងឺទេ ដូចនេះ អ្នកជម្ងឺនោះ ប្រហែលជាមិនអាចរស់បានយូរទេ។

សូមគិតអំពីរឿងមនុស្សខ្វាក់៦នាក់ ដែលគេឲ្យប៉ះសត្វដំរី ដោយមិនបានប្រាប់ពួកគេថា វាជាសត្វដំរី។ ពួកគេក៏បានព្យាយាមពិពណ៌នា អំពីអ្វីដែលខ្លួនកំពុងតែប៉ះ។ រឿងប្រៀបធៀបនេះច្រើនតែត្រូវបានប្រើប្រាស់ ដើម្បីរំឭកយើង ឲ្យជៀសវាងការអះអាង អំពីសេចក្តីពិតដាច់ខាត ជាពិសេសអំពីព្រះ។ បុរសខ្វាក់ភ្នែកទាំងនោះបានធ្វើការសន្និដ្ឋានខុសៗគ្នា អំពីសត្វដំរី ដោយខ្លះថា វាជាដើមឈើ ខ្លះថាសត្វពស់ ខ្លះថា ផ្ចិត ហើយខ្លះថាជាជញ្ជាំង គឺផ្អែកទៅលើផ្នែកនៃរូបកាយរបស់សត្វដំរី ដែលពួកគេបានប៉ះ។ រឿងនេះបានបង្រៀនយើងថា សមត្ថភាពរបស់មនុស្សមានកំណត់ នៅក្នុងយល់ដឹង អំពីអ្វីដែលគ្មានដែនកំណត់ ដូចនេះ យើងមិនអាចធ្វើការសង្កេតឲ្យបានសុក្រិត អំពីព្រះបានឡើយ។

ទោះជាយ៉ាងណាក៏ដោយ បើអ្នកគិតអំពីការសន្និដ្ឋាននេះ ជាបន្ថែមទៀត តែបន្តិច អ្នកអាចដឹងថា ការយល់ស្របមតិអ្នកដទៃ ដើម្បីឲ្យឆាប់ចប់រឿង គឺមានពេញដោយបញ្ហា គ្រប់កំរិត គឺទាំងក្នុងកំរិតហេតុផល ការប្រៀបធៀប និងផ្នែកទេវសាស្រ្ត។

ឧបមាថា បុរសពិការភ្នែកទាំង៦នាក់បានជួបជុំគ្នា ដើម្បីពិភាក្សា អំពីអ្វីដែលពួកគេបានប៉ះ។ តើពួកគេនឹងធ្វើការសន្និដ្ឋានថា វាជាសត្វដំរីឬ? ខ្ញុំមិនជឿថា ពួកគេនឹងសន្និដ្ឋានដូចនេះឡើយ។ ប៉ុន្តែ តើរឿងនេះមានន័យថា សត្វដំរីមិនមានវត្តមាន ពេលដែលពួកគេកំពុងស្ទាបប៉ះឬ? តើសត្វដំរី និងដើមឈើជាវត្ថុតែមួយឬ?

និយាយឲ្យត្រូវតាមទេវសាស្រ្ត អ្នកដែលអាចដោះស្រាយបញ្ហានេះបាន ហើយផ្តល់ឲ្យនូវចម្លើយដ៏សុក្រឹត គឺជាអ្នកដែលអាចមើលឃើញសត្វដំរីនោះទាំងមូល។ យ៉ាងណាមិញ តាមគំរូនៃរឿងប្រៀបធៀបនេះ ដើម្បីឆ្លើយសំណួរដែលសួរ

ថា "តើសាសនាទាំងអស់ សុទ្ធតែនាំយើងទៅរកព្រះឬ?" នោះយើងត្រូវតែសួរថា បើសមត្ថភាពនៃចំណេះដឹងរបស់មនុស្សម្នាក់ៗសុទ្ធតែមានកំណត់ តើនរណា ឬ មានអ្វីអាចនាំយើងទៅរកសេចក្ដីពិត ដែលចែងអំពីព្រះ?

## រឿងសត្វដំរី : ការបកស្រាយខុសគ្នា?



*បើសមត្ថភាពនៃចំណេះដឹងរបស់មនុស្សម្នាក់ៗ សុទ្ធតែមានកំណត់ តើនរណា ឬមានអ្វីអាចនាំយើងទៅរកសេចក្ដីពិត ដែលចែងអំពីព្រះ ?*

អ្វីដែលចម្លែកនោះគឺ សព្វថ្ងៃនេះ រឿងបុរសខ្វាក់ទាំង៦ និងសត្វដំរីត្រូវបានគេប្រើប្រាស់ កុំឲ្យមនុស្សធ្វើការលើកដំកើងសេចក្ដីពិតដែលដាច់ខាត ឬការអះអាងផ្ដាច់មុខបែបសាសនា ប៉ុន្តែ គេមិនតែងតែយករឿងនេះប្រើយ៉ាងដូចនេះឡើយ។

យើងមិនដឹងថា រឿងនេះមានប្រភពមកពីណាទេ ហើយកាលពីដើមដំបូងបំផុត គេបានប្រើវាយ៉ាងដូចម្ដេចឡើយ ប៉ុន្តែ យើងអាចដឹងថា ព្រះពុទ្ធដែលជាអ្នកបង្កើតសាសនាព្រះពុទ្ធ បានប្រើវា ដើម្បីធ្វើការសន្និដ្ឋានខុសពីនេះទាំងស្រុង។ លោកបង្រៀនថា មនុស្សដែលសន្និដ្ឋានថា ទស្សនៈរបស់ខ្លួនគឺជាសេចក្ដីពិត គឺមិនខុសពីមនុស្សខ្វាក់ ដែលព្យាយាមពិពណ៌នាថាសត្វដំរី គឺជាដើមឈើ សត្វពស់ ផ្លិត ឬជញ្ជាំង។ ការសន្និដ្ឋានរបស់ពួកគេសុទ្ធតែខុស ព្រោះតាមពិត មានសេចក្ដីពិតដែលដាច់ខាត ដែលបញ្ជាក់ថា វាជាសត្វដំរី។

យើងអាចដឹងថា សមត្ថភាពក្នុងការយល់ដឹងរបស់បុរសខ្វាក់ទាំងនោះ គឺមានកំណត់។ ប៉ុន្តែ វាមិនមានន័យថា សេចក្ដីពិត ឬសត្វដំរី មិនមានក្នុងពិភពលោកនោះឡើយ។

តាមការបកស្រាយដូចនេះ រឿងប្រៀបធៀបអំពីបុរសខ្វាក់ភ្នែក និងសត្វដំរី គឺមិនបានលើកកម្ពស់សេចក្តីពិត ដែលផ្តេកផ្តួលទៅលើការគិតរបស់មនុស្សនោះឡើយ ប៉ុន្តែ ពិតជាបានលើកទឹកចិត្តយើង ឲ្យមានការទទួលខុសត្រូវ នៅក្នុងការស្គាល់សេចក្តីពិត។

អ្នកអាចមើលដឹងថា រឿងនេះបាននាំមកនូវបញ្ហាប្រឈមដ៏សំខាន់ ដល់អ្នកដែលគិត អំពីសេចក្តីពិតខាងវិញ្ញាណ។ ដូចដែលរឿងអំពីអ្នកជំងឺមហារីកសួត និងរឿងបុរសខ្វាក់ទាំង៦ និងសត្វដំរីបានបកស្រាយហើយ សេចក្តីពិតមិនអាស្រ័យទៅលើការគិតរបស់មនុស្សម្នាក់ៗនោះឡើយ។ ហើយយើងមិនអាចស្គាល់សេចក្តីពិតឲ្យអស់ តែមិនមានន័យថា យើងមិនអាចយល់សេចក្តីពិតឲ្យបានត្រឹមត្រូវនោះទេ។



*ទី៣*

# តើសាសនាទាំងអស់សុទ្ធតែបង្រៀនដូចគ្នាឬ?

សា**សានាទាំងអស់ អាចបង្រៀនខុស។** ប៉ុន្តែ តើសាសនាទាំងអស់ អាចត្រូវដូចគ្នាដែរឬទេ? ដើម្បីឆ្លើយសំណួរនេះ សូមយើងពិចារណា អំពីការបកស្រាយជាមូលដ្ឋាន អំពីព្រះ នៅក្នុងសាសនាធំៗមួយចំនួន នោះអ្នកនឹងបានដឹងថា សាសនាទាំងនោះមិនបាននិយាយដូចគ្នាឡើយ។ ឥឡូវនេះ សូមយើងស្វែងយល់អំពីជំនឿ និងសាសនាធំៗមួយចំនួន ដែលរាប់បញ្ចូលទាំងលទ្ធិដែលមិនជឿថាព្រះមានពិតមែន ព្រោះលទ្ធិនេះក៏មានការបកស្រាយជាច្រើន អំពីព្រះផងដែរ។

លទ្ធិដែលមិនជឿថាព្រះមានពិតមែន បានបដិសេធជំនឿទាំងអស់ ដែលជឿថាព្រះពិតជាមានមែន តែសាសនាហិណ្ឌូបានជឿថា មានព្រះជាច្រើនអង្គ។ សាសនាព្រះពុទ្ធវិញ មានប្រភពចេញពីការបដិសេធសាសនាហិណ្ឌូ មាននិកាយដែលមិនបង្រៀនឲ្យថ្វាយបង្គំព្រះពុទ្ធ និងនិកាយដែលលើកទឹកចិត្តឲ្យថ្វាយបង្គំព្រះពុទ្ធ។ សាសនាអ៊ីស្លាម សាសនាយូដា(ជ្វីប) និងជំនឿគ្រីស្ទបរិស័ទ បានជឿដូចគ្នាថា ព្រះពិតមានតែមួយ។ សាសនាអ៊ីស្លាមជឿថា ព្រះពិតដាច់ខាត តែជំនឿរបស់គ្រីស្ទបរិស័ទបានជឿថា ព្រះពិតមានបីអង្គ ដែលរួមមកជាព្រះតែមួយ។

ជំនឿសាសនាទាំងអស់នេះ បានឲ្យនិយមន័យខុសៗគ្នា អំពីជីវិត និងដើមកំណើរនៃជីវិត។



*សាសនាអ៊ីស្លាម សាសនាយូដា(ជ្វីប) និងជំនឿគ្រីស្ទបរិស័ទជឿយ៉ាងមាំថា មនុស្សមិនមែនកើតដោយចៃដន្យ ឬជាការស្រមើស្រមៃនោះឡើយ។*

អ្នកដែលមិនជឿថាព្រះមានពិតមែន បានជឿថា អ្វីដែលយើងមើលឃើញ រាប់ចាប់តាំងពីរុក្ខជាតិ សត្វ និងជីវិតមនុស្ស គឺបានកើតឡើងពីដំណើរការដែលកើតមានដោយចៃដន្យ។ សាសនាហិណ្ឌូជឿថា ជីវិតរបស់មនុស្សគឺជាការវិលកើតវិលស្លាប់ ហើយបានបកស្រាយថា បើនិយាយឲ្យដល់ចំណុចស្នូលនៃជីវិត ជីវិតគឺជាការស្រមើលស្រមៃ។ សាសនាព្រះពុទ្ធក៏ជឿស្រដៀងនេះដែរ អំពីការចាប់ជាតិ ប៉ុន្តែ ជឿថា បើនិយាយដល់ចំណុចស្នូលនៃជីវិត ជីវិតគឺជាទុក្ខវេទនា ដូចនេះ គោលដៅធំបំផុត នៃជីវិត គឺត្រូវទៅឲ្យដល់ស្ថាននិពាន្ត។ ពាក្យនិព្វាន គឺជាភាសាសំស្ក្រឹត មានន័យ ថា ចេញឲ្យផុតស្រឡះ គឺបានសេចក្តីថា បុគ្គលម្នាក់ៗមិនមានអ្វីខុសគ្នាឡើយ ពេលដែលពួកចូលទៅដល់ភាពជាអបុគ្គល នៃភាពទទេ។

សាសនាព្រះពុទ្ធបង្រៀនសាសនិករបស់ខ្លួន ឲ្យដើរតាមមាគ៌ារបស់ព្រះពុទ្ធ ក្នុងការប្រតិបត្តិអរិយដ្ឋង្គិកមគ្គ ទាំង៨ ខណៈពេលដែលសាសនាតៅបង្រៀនថា តៅ គឺជា “ផ្លូវតែមួយ” សម្រាប់ឲ្យមនុស្សសម្រេចឲ្យបាននូវលក្ខណៈពិតប្រាកដរបស់ខ្លួន ដើម្បីវិលត្រឡប់ទៅរក “ភាពជារូបមួយ” ដែលសុទ្ធល្អ។ សាសនាអ៊ីស្លាម សាសនាយូដា(ជ្វីប) និងជំនឿគ្រីស្ទបរិស័ទជឿយ៉ាងមាំថា មនុស្សមិនមែនកើតដោយចៃដន្យ ឬជាការស្រមើស្រមៃនោះឡើយ។ ពួកគេជឿថា មនុស្សជាតិ និងសត្វលោកទាំងអស់ គឺជាស្នាព្រះហស្តនៃព្រះអាទិករ ដែលមានប្រាជ្ញាញាណ។ ប៉ុន្តែ ខណៈពេលដែលសាសនាយូដា(ជ្វីប) និងជំនឿគ្រីស្ទបរិស័ទបានបង្រៀនថា

ព្រះបានបង្កើតមនុស្ស ឲ្យត្រូវរូបអង្គទ្រង់ សាសនាអ៊ីស្លាមបានបដិសេធដាច់ខាត ចំពោះការជឿថា ព្រះនិងមនុស្សមានលក្ខណៈដែលស្រដៀងគ្នា។

អ្នកអាចអានបន្ថែមទៀត ដោយខ្លួនឯង អំពីសាសនាទាំងនោះ នៅក្នុងវេបសាយ នៅទំព័របន្ទាប់។

ដោយសារជំនឿសាសនានីមួយៗមានការបង្រៀនជាមូលដ្ឋានខុសៗគ្នា ដូចនេះ គេមិនគួរសួរឡើយថា “តើសាសនាទាំងអស់សុទ្ធតែដូចគ្នាឬ?” បើយើងចង់សួរ គួរតែសួរដូចនេះវិញថា តើគេអាចឈានទៅដល់ស្ថានមូកធិ នៃសាសនាហិណ្ឌូ ដោយកាន់តាមសាសនាតៅ ទៅដល់ស្ថាននិព្វានដោយកាន់តាមសាសនាខុងជឺ ឬក៏មានជីវិតអស់កល្បបានឡើយ បើមិនបានដើរតាមព្រះយេស៊ូវគ្រីស្ទឬ? ពួកគេមានចំណុចខុសគ្នាដែលស៊ីជម្រៅ ដូចនេះ បើយើងចាត់ទុកសាសនាទាំងអស់សុទ្ធតែបង្រៀនត្រូវ គឺបានប្រាសចាកសេចក្ដីពិតហើយ។

វាអាចមានការពិបាក នៅក្នុងការពិពណ៌នា អំពីជំនឿសាសនានីមួយៗ ហើយនិយាយសង្ខេបអំពីជំនឿ និងគោលតម្លៃរបស់ជំនឿសាសនាទាំងនោះ ឲ្យបានត្រឹមត្រូវ និងសុក្រឹត ព្រោះមានការកាត់ស្រាយខុសៗគ្នា សម្រាប់ទ្រឹស្ដីក្នុងសាសនាទាំងនោះ។

អ្នកអាចអានបន្ថែម អំពីសាសនាទាំងនោះ តាមបណ្ដាញអ៊ីនធើណិត តាមអាស័យដ្ឋានខាងក្រោម :

សាសនាហិណ្ឌូ

www.britannica.com/topic/Hinduism

www.hinduismtoday.com/

www.thehinduhub.org/resources/downloads

សាសនាព្រះពុទ្ធ

thebuddhistcentre.com/buddhism

www.buddhanet.net/e-learning/5minbud.htm

www.britannica.com/topic/Buddhism

សាសនាតៅ

www.taoism.org.sg

www.iep.utm.edu/daoism/

www.taoist.org/taoism-cultivating-body-mind-spirit/

សាសនាអ៊ីស្លាម

www.whyislam.org/

www.islamreligion.com/

www.islamicity.org/8304/understanding-islam-and-muslims/

សាសនាយូដា(ជ្វីប)

www.chabad.org/library/article_cdo/aid/3710122/jewish/What-Is-Judaism.htm

www.myjewishlearning.com/article/judaism/

www.oneforisrael.org/bible-based-teaching-from-israel/judaism/



ទី ៤

# ហេតុអ្វីសេចក្ដីពិតមានភាពដាច់ខាត?

**នៅក្នុងការស្រាវជ្រាវរកសេចក្ដីពិត** ជាញឹកញាប់ យើងច្រើនតែនិយាយថា យើងមិនត្រូវតែឯងទេ ព្រោះយើងចង់បង្ហាញការគោរព ចំពោះសេចក្ដីពិតរបស់អ្នកដទៃ។ ឧទាហរណ៍ យើងនិយាយថា “អ្នកនិយាយត្រូវ ហើយខ្ញុំក៏និយាយត្រូវដែរ”។ ប៉ុន្តែ ក្នុងគំនិតយើង យើងមិនបានគិតដូចនេះទេ មែនទេ? ព្រោះជាធម្មតា យើងចង់ប្រកាន់ខ្ជាប់នូវអ្វីដែលយើងជឿថាត្រូវ ហើយជំរុញអ្នកដទៃឲ្យទទួលស្គាល់ថា ជំនឿរបស់យើង មានភាពត្រឹមត្រូវ ទោះគេមិនយល់ស្របយ៉ាងណាក៏ដោយ។

បើយើងបដិសេធការអះអាង អំពីសេចក្ដីពិតដែលដាច់ខាត ហើយបដិសេធថា ផ្លូវត្រូវមិនមែនដាច់ខាត ដោយទទូចថា យើងគួរតែចាត់ទុកសាសនាទាំងអស់ថា ត្រូវដូចគ្នា នោះមានន័យថា តើធ្វើដូចនេះ ជាទង្វើរត្រឹមត្រូវឬទេ? អ្នកដែលធ្វើការអះអាងអំពីសេចក្ដីពិតអ្វីមួយ សូម្បីតែអ្នកដែលនិយាយថា សេចក្ដីពិតមានការផ្ដេកផ្ដួលទៅលើការគិតរបស់មនុស្ស គឺកំពុងតែអះអាងថា ខ្លួនឯងនិយាយត្រូវ។

ជាការពិតណាស់ យើងប្រហែលជានិយាយថា យើង “សុខចិត្តយល់ស្របគំនិតគេ ដើម្បីឲ្យឆាប់ចប់រឿង” ពេលដែលអ្នកដទៃមានទស្សនៈខុសពីយើង។

ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រនេះច្រើនតែផ្អែកទៅលើការគួរសម(ឬល្បិច) ជាជាងធ្វើតាមជំនឿរបស់ខ្លួន។ ពេលណាយើងអះអាងថា យើងគោរពគ្នាទៅវិញទៅមក តាមពិត យើងនៅតែជំរុញគ្នាទៅវិញទៅមក ឲ្យទទួលយកជំនឿ "ផ្ទាល់ខ្លួន" របស់យើង។

ទោះជាយ៉ាងណាក៏ដោយ សេចក្ដីពិតនៅតែសំខាន់។ បើយើងប្រកាន់ខ្ជាប់ជំនឿថា យើងម្នាក់ៗអាចកំណត់សេចក្ដីពិតខុសៗគ្នា និងរៀបចំជីវិតខ្លួនឯង តាមសេចក្ដីពិតរៀងៗខ្លួន នោះបញ្ហានេះ នឹងមានផលប៉ះពាល់មកលើក្រមសីលធម៌របស់សង្គមមិនខាន។ ពេលនោះ យើងអាចចាប់ផ្ដើមលើកកម្ពស់ជម្រើសផ្ទាល់ខ្លួន ដោយមិនគិតប្រយោជន៍អ្នកដទៃ ដោយរស់នៅតាមផ្លូវរបស់យើង តាម "សេចក្ដីពិត" របស់យើង ទោះអ្នកដទៃរងគ្រោះក៏ដោយ។

ក្នុងភាសាអង់គ្លេស មានសំនួនវោហាមួយ ដែលពោលថា "សាច់គោរបស់មនុស្សម្នាក់ គឺជាថ្នាំពល់របស់មនុស្សម្នាក់ទៀត"។ ពាក្យមួយឃ្លានេះ គឺបានបង្រៀនថា យើងម្នាក់ៗមានជម្រើសខុសៗគ្នា ដែលយើងគួរតែគោរព។ ទោះជាយ៉ាងណាក៏ដោយ បើយើងប្រើឃ្លានេះ ក្នុងន័យត្រង់ នោះសេចក្ដីពិតដែលដាច់ខាត គឺពិតជាសំខាន់ណាស់! បានសេចក្ដីថា បើសាច់នោះគឺជាថ្នាំពុលសម្រាប់ខ្ញុំ ហើយខ្ញុំបានសម្រេចចិត្តបរិភោគវា តែអ្នកបានផ្ដល់ការគោរពចំពោះការសម្រេចចិត្តរបស់ខ្ញុំ នោះខ្ញុំនឹងមានគ្រោះថ្នាក់។

អ្នកអាចមើលដឹងថា អ្នកខ្លះមានការយល់ច្រឡំ អំពីទស្សនៈ និងចំណេះដឹង។ ចំណេះដឹង គឺជាសមត្ថភាពនៅក្នុងការពិពណ៌នាអំពីអ្វីមួយ តាមភាពជាក់ស្ដែងរបស់វា តែទស្សនៈគឺជាអ្វីដែលយើងយល់ឃើញដោយសេរី អំពីអ្វីមួយ ដោយមិនអាស្រ័យទៅលើចំណេះដឹងរបស់យើង។ ពេលណាយើងមានការឡូកឡំគ្នារវាងទ

ស្សនៈ និងចំណេះដឹង ហើយយល់ច្រឡំថា ទស្សនៈ គឺជាចំណេះដឹង នោះយើងក៏មានអារម្មណ៍ថា យើងមានសេរីភាព នៅក្នុងការកំណត់ថា អ្វីពិតឬមិនពិត តាមចិត្តយើង។ ហើយបើសេចក្តីពិត គ្រាន់តែជាអ្វីដែលមនុស្សម្នាក់កំណត់ថា ពិត ឬមិនពិត យើងនឹងគ្មានអ្វីដែលជាសេចក្តីពិត ដ៏ជាក់លាក់នោះឡើយ។



*ចំណេះដឹង គឺជាសមត្ថភាពនៅក្នុងការពិពណ៌នាអំពីអ្វីមួយ តាមភាពជាក់ស្តែងរបស់វា តែទស្សនៈគឺជាអ្វីដែលយើងយល់ឃើញដោយសេរី អំពីអ្វីមួយ ដោយមិនអាស្រ័យទៅលើចំណេះដឹងរបស់យើង។*

## **បញ្ហានៃភាពខុសគ្នា?**

ដើម្បីជៀសវាងកុំឲ្យគេអាក់អន់ចិត្ត ដោយសារយើងប្រកាន់ថា ខ្លួនឯងត្រូវ យើងប្រហែលជាចង់បដិសេធសេចក្តីពិត។ ការនេះគឺមិនខុសពីការនិយាយថា “យើងអាចយល់ស្របចំពោះមតិគេ ដើម្បីឲ្យឆាប់ចប់រឿង ព្រោះសេចក្តីពិតមិនសំខាន់ទេ”។

ប៉ុន្តែ សូមពិចារណាថា បើយើងមិនខ្វល់ថា សេចក្តីពិតដាច់ខាតពិតជាមានមែន ឬអត់ ហើយគិតថា ខ្លួនយើងអាចកំណត់ ឬចងក្រងសេចក្តីពិត អំពីសាសនាទាំងអស់ ដោយខ្លួនឯងបាន តើយើងមិនកំពុងតែមានគំនិតវាក់កំផែលទេឬ? យើងបានដឹងហើយថា សាសនាទាំងអស់មិនមានការបង្រៀនដូចគ្នា អំពីព្រះនោះទេ។

តើការមិនខ្វល់ អំពីសេចក្តីពិតដាច់ខាត មិនមែនជាបញ្ហាពិតប្រាកដទេឬ? តើនេះមិនមែនជាមូលហេតុ ដែលនាំឲ្យមនុស្សចូលចិត្តគិតថា សាសនាទាំងអស់នាំទៅរកព្រះតែមួយ? មិនមែនដោយសារយើងមិនដឹងថា វាមិនមែនជាការពិត តែដោយសារយើងចង់ឲ្យវាក្លាយជាការពិត? តើយើងមិនត្រូវគិតអំពីរឿងនេះឲ្យបានច្បាស់ទេឬ?

នៅក្នុងដំណើរឆ្ពោះទៅរកសេចក្តីពិត សូមយើងចាំថា ការប្រកាន់ខ្ជាប់ថា សេចក្តីពិតដាច់ខាត ពិតជាមានមែន មិនមែនជាបញ្ហានោះទេ ការមិនខ្វល់ថា សេចក្តីពិតដាច់ខាតមានមែនឬអត់ ទើបជាបញ្ហា។ ពុំនោះទេ យើងប្រហែលជាត្រូវគេបង្រៀន ឬនាំឲ្យជឿថា សាសនាទាំងអស់សុទ្ធតែនាំទៅរកព្រះតែមួយ ឬយើងត្រូវគេបង្រៀនតាំងពីតូចមក ឲ្យមានការទ្រាំទ្រចំពោះទស្សនៈរបស់អ្នកដទៃ ដោយមិនខ្វល់អំពីសេចក្តីពិត។ ប៉ុន្តែ បើយើងមិនខ្វល់ថា សេចក្តីពិតដាច់ខាតមានពិតមែនឬអត់ តើយើងអាចបន្តមានចិត្តសណ្តោសចំពោះអ្នកដទៃឬទេ?



*ទី៥*

# ហេតុអ្វីបានជាយើងជឿ?

**តើអ្នកធ្លាប់ឆ្ងល់ទេថា** : ហេតុអ្វីមនុស្សមានការប្រឆាំង ចំពោះអ្នកដែលអះអាងដាច់ខាតថា មានតែសាសនារបស់ខ្លួនទេ ដែលត្រូវ? ខ្ញុំជឿថា ការប្រឆាំងនេះបានកើតមានឡើង ដោយសារពួកគេបានគិតអំពីការអះអាងនោះដោយផ្អែកទៅលើឥរិយាបថ នៃបញ្ហាបីយ៉ាង គឺជំនឿខុស អំណួតលាក់មុខ និងការជឿទាំងច្រឡំ។ តាមពិត ឥរិយាបថទាំងបីនេះមានការទាក់ទងគ្នា។

## ការមានជំនឿខុស

មនុស្សជាច្រើនបានសន្និដ្ឋានថា សាសនាទាំងអស់នាំទៅរកព្រះតែមួយ។ ពួកគេសន្និដ្ឋានដូចនេះ គឺដោយសារពួកគេមិនមានការយល់ដឹងច្បាស់លាស់ អំពីសាសនានីមួយៗ។ ពួកគេហាក់ដូចជាជឿថា សាសនាធំៗប្រាកដជាដូចគ្នាហើយ ព្រោះសាសនាទាំងនោះសុទ្ធតែបង្រៀនយើងឲ្យធ្វើអំពើល្អ ស្រឡាញ់ បម្រើអ្នកដទៃ ជួយអ្នកទន់ខ្សោយ មិនធ្វើអាក្រក់មកលើអ្នកដទៃ ហើយនិយាយការពិត។ ដូចនេះ ពួកគេក៏បានសន្និដ្ឋានថា សាសនាទាំងនោះប្រាកដជាត្រូវដូចគ្នា។

ទោះជាយ៉ាងណាក៏ដោយ ទស្សនៈខាងលើនេះ គឺមិនបានគិតដល់គោលទ្ធិ និង គោលការណ៍ ដែលជាមូលដ្ឋានគ្រឹះនៃសាសនាទាំងនោះ ដូចដែលយើងបាន ឃើញក្នុងទំព័រមុនៗនោះឡើយ។ ទស្សនៈនេះមិនចង់បដិសេធថា សាសនាណា មួយបង្រៀនខុសនោះឡើយ គឺដោយសារគេមានជំនឿខុសថា សាសនាទាំងអស់ ប្រាកដជាត្រូវដូចគ្នា។

## អំណួតដែលលាក់មុខ



*ពួកគេយល់ឃើញថា ការអះអាងថា សាសនាណាមួយត្រឹមត្រូវ ហើយ សាសនាដទៃទៀតខុស គឺជាការអះអាងបែបអញ្ញនិយម។*

មានអ្នកខ្លះទៀតជឿថា ការនិយាយថា ផ្លូវពិតមាន តែមួយ គឺជាការនិយាយខុស។ ពួកគេយល់ឃើញថា ការអះអាងថា សាសនាណាមួយត្រឹមត្រូវ ហើយ សាសនាដទៃទៀតខុស គឺជាការអះអាងបែបអញ្ញនិយម។ ពួកគេលើកហេតុផលថា គ្មានមនុស្សណាដែលល្អឥត ខ្ចោះទេ ដូចនេះ តើយើងជានរណា ដែលហ៊ាននិយាយថា អ្វីមួយត្រូវ ឬខុសនោះ?

ទោះជាយ៉ាងណាក៏ដោយ ពេលដែលពួកគេអះអាង ថា “ផ្លូវទាំងអស់ សុទ្ធតែនាំទៅរកសេចក្ដីពិតតែមួយ” តើពួកគេមិនកំពុងតែអះ អាងថា ខ្លួនចេះជាងអ្នកបង្កើតសាសនាទាំងនេះទេឬ? អ្នកបង្កើតជំនឿសាសនា ទាំងនោះ ដែលរួមមានព្រះពុទ្ធ មហាម៉ាត់ ឬព្រះយេស៊ូវ សុទ្ធតែបានអះអាងរៀង ៗខ្លួន ផ្លូវពិតមានតែមួយ ក្នុងជំនឿ ឬសាសនារបស់ខ្លួន។ ដូចនេះ ការអះអាងថា ផ្លូវទាំងអស់សុទ្ធតែនាំទៅរកសេចក្ដីពិតតែមួយ មិនមែនជាអំណួតដែលលាក់មុខ ទេឬ?

# ការជឿទាំងច្រឡំ

ខ្ញុំជឿថា នៅពីក្រោយឥរិយាបថពីរដំបូង គឺមានឥរិយាបថមួយទៀត គឺ ការជឿទាំងច្រឡំ ។ មានពេលមួយនោះ ខ្ញុំបានសួរបុរសម្នាក់ថា “តើសាសនាទាំងអស់សុទ្ធតែបង្រៀនសេចក្តីពិតដូចគ្នាឬ?។ ពេលខ្ញុំសួរគាត់ គាត់ក៏បានទម្លាក់ទឹកមុខ។ គាត់សួរខ្ញុំវិញថា “អ្នកជាជនជាតិឥណ្ឌា ហេតុអ្វីអ្នកសួរសំណួរដូចនេះ? ខ្ញុំជឿថា អ្នកប្រាកដជាធ្លាប់យល់ អំពីអ្វីដែលលោកមហាត្មះ គន្ធី បាននិយាយហើយមែនទេ”។

លោកគន្ធីបានដឹកនាំចលនាទាមទារឯករាជ្យឲ្យប្រទេសឥណ្ឌា ហើយត្រូវបានគេទទួលស្គាល់ជាទូទៅថា គាត់ជាបិតាជាតិ។ គាត់ជឿថា សាសនាទាំងអស់សុទ្ធតែដូចគ្នា ក្នុងការបង្រៀនជាមូលដ្ឋាន។ តាមពិត បុរសនោះបានលើកយកឈ្មោះរបស់លោកគន្ធីមកនិយាយ ដោយសារខ្ញុំជាជនជាតិឥណ្ឌា។ ការឆ្លើយតបរបស់បុរសនេះ គឺជារឿងធម្មតាទេ ព្រោះមនុស្សជាច្រើនមានការយល់ដឹង អំពីសេចក្តីពិត តាមរបៀបនេះឯង។ គេទទួលស្គាល់ថា វាជាសេចក្តីពិត ព្រោះមនុស្សជាច្រើនបានទទួលស្គាល់វាជាសេចក្តីពិត។

អ្នកប្រហែលជាដឹងហើយថា អ្វីដែលគេពេញនិយម មិនមែនសុទ្ធតែជាសេចក្តីពិតនោះទេ។ ហេតុអ្វីមនុស្សគិតថា អ្វីដែលគេពេញនិយម គឺជាអ្វីដែលត្រឹមត្រូវ? ខ្ញុំមិនបាននិយាយថា សម្លេងភាគច្រើន ជាការអាក្រក់នោះទេ។ មនុស្សជាច្រើនដែលជឿថា សាសនាទាំងអស់នាំមនុស្សទៅរកព្រះតែមួយ គឺជាមនុស្សដែលមានចិត្តល្អ មានបញ្ញា ហើយស្មោះត្រង់។ ប៉ុន្តែ ភាពស្មោះត្រង់របស់មនុស្សមិនមែនជាកត្តាកំណត់នៃសេចក្តីពិត គឺមិនខុសពីភាពពេញនិយមនោះឡើយ។ ខ្ញុំ



*តើធ្វើដូចម្តេច ឲ្យយើងអាចយល់ច្បាស់ អំពីអ្វីមួយ អំពីសាសនា ឬអំពីព្រះ?*

អាចមានភាពស្មោះត្រង់ នៅក្នុងរឿងដែលមិនពិត។ ជាការពិតណាស់ លោកគន្ធីជាបុគ្គលដែលមានភាពឧត្តុងឧត្តម្ភជាងគេ ក្នុងចំណោមជនរួមជាតិរបស់គាត់ ហើយក្នុងនាមខ្ញុំជាជនជាតិឥណ្ឌា ខ្ញុំមានសិទ្ធិសេរីភាព ក៏ដោយសារការលះបង់របស់លោកគន្ធី ដោយចិត្តក្លាហាន និងមិនអាត្មានិយម។ ប៉ុន្តែ តើការនេះមានន័យថា គាត់បាននិយាយត្រូវ អំពីភាពដូចគ្នា នៃសាសនាទាំងអស់ទេឬ?

លោកគន្ធីបានទទួលឥទ្ធិពលយ៉ាងខ្លាំង ពីការបង្រៀនរបស់ព្រះយេស៊ូវ ជាពិសេសសេចក្តីអធិប្បាយនៅលើភ្នំ។ ប៉ុន្តែ គាត់មិនបានទទួលយកជំនឿរបស់គ្រីស្ទបរិស័ទ តាមគោលលទ្ធិនៃជំនឿរបស់គ្រីស្ទបរិស័ទនោះឡើយ។ គាត់គ្រាន់តែបានរើសយក តែផ្នែកណាមួយ របស់ជំនឿគ្រីស្ទបរិស័ទ ដែលគាត់ពេញចិត្ត ហើយធ្វើការកាត់ស្រាយផ្នែកនោះឡើងវិញ តាមទស្សនៈរបស់គាត់ ជាសាសនិកហិណ្ឌូ។ គាត់ក៏បានធ្វើដូចនេះ ចំពោះការបង្រៀនរបស់ព្រះពុទ្ធផងដែរ ដែលគាត់បានទទួលស្គាល់ថា ជាអ្នកកែទម្រង់ដ៏អស្ចារ្យ នៃសាសនាហិណ្ឌូ។

បានសេចក្តីថា លោកគន្ធីបានពិចារណា អំពីសេចក្តីពិត ដែលត្រូវបានអះអាងដោយសាសនាទាំងឡាយ តាមទស្សនៈរបស់អ្នកដើរតាមគាត់ គឺមិនមែនតាមទស្សនៈរបស់ស្ថាបនិកនៃសាសនាទាំងនោះឡើយ។ ដូចនេះ តើការជឿគាត់ មិនខុសពីការជឿទាំងយល់ច្រឡំទេឬ? តើយើងមិនលំអៀងទៅខាងសាសនាណាមួយ ដោយសារយើងជឿថា អ្នកបង្កើតសាសនានីមួយៗ សុទ្ធតែត្រូវឬ(ឬមិនអាចខុស)?

ដើម្បីលើកយកបញ្ហានេះមកនិយាយ យើងចាំបាច់ត្រូវពិចារណាសំនួរនេះ : តើធ្វើដូចម្ដេច ឲ្យយើងអាចយល់ច្បាស់ អំពីអ្វីមួយ អំពីសាសនា ឬអំពីព្រះ?



*ទី៦*

# តើយើងអាចស្វែងរកសេចក្ដីពិត ដោយរបៀបណា?

**មុនពេលយើងចាប់ផ្ដើមស្វែងយល់អំពីអ្វីមួយ** ជាបឋម យើងត្រូវធ្វើការសន្និដ្ឋានជាមូលដ្ឋានមួយថា យើងអាចយល់ដឹង អំពីវាបាន។ បន្ទាប់មក យើងអាចស្វែងរកចំណេះដឹង អំពីអ្វីមួយនោះ ឬអំពីអង្គបុគ្គលនោះ។ យើងអាចរកបានចំណេះដឹងនោះ តាមមធ្យោបាយផ្សេងៗ។ ឧទាហរណ៍ យើងមានការយល់ដឹងអំពីច្បាប់នៃទំនាញផែនដី ខុសពីការយល់ដឹងរបស់យើង អពីសេចក្ដីស្រឡាញ់របស់មនុស្សដែលជិតស្និទ្ធនឹងយើង។ យ៉ាងហោចណាស់ មនុស្សអាចទទួលចំណេះដឹង តាមផ្លូវ៥យ៉ាង ដែលមានដូចជា សភាវគតិ ការសង្កេត បទពិសោធន៍ ប្រវត្តិសាស្ត្រ(ប្រពៃណី) និងការបើកបង្ហាញ។

**សភាវគតិ** គឺជាការយល់ដឹងឬដឹងអ្វីមួយភ្លាមៗ ដោយមិនចាំបាច់ឆ្លងកាត់ការគិត ការវិចារណា ឬការពិសោធន៍។ ពួកទស្សនវិទូបានហៅសភាវគតិថាជាចំណេះដឹងដែលមានជាមុន ជាអ្វីដែលយើងមានរួចជាស្រេច មុនពេលដែលយើងត្រូវប្រើវា។ វាមិនអាស្រ័យទៅលើបទពិសោធន៍នោះឡើយ។

ឧទាហរណ៍ សភាវគតិ ដែលទាក់ទងនឹងសម្រស់។ បើខ្ញុំសួរអ្នក “តើផ្កាកុលាស្អាតទេ?” អ្នកអាចដឹងច្បាស់ថា ខ្ញុំមិនមែនកំពុងតែសុំឲ្យអ្នកឆ្លើយ ដោយផ្អែកទៅលើអ្វីដែលទើបតែបានកើតឡើងចំពោះភ្នែករបស់អ្នកនោះឡើយ។ ជាការពិតណាស់ ភ្នែករបស់យើងផ្តោតទៅលើកាំរស្មី ដែលផ្លាតចេញពីផ្កាកូឡាបមក ហើយក៏បានបង្កើតជារូបភាពមួយ នៅលើប្រស្រីភ្នែក ដែលបញ្ជូនពត៌មានទៅខួរក្បាល ឲ្យដឹងថា វាបានឃើញរូបភាពអ្វី។ ប៉ុន្តែ សភាវគតិរបស់យើងនាំឲ្យយើងដឹងថា វាស្អាត ដោយមិនបាច់ចាំគិតជាមុន អំពីវា ហើយយើងក៏ប្រើសភាវគិត ដើម្បីវិនិច្ឆ័យអ្វីដែលយើងឃើញ។



*ចំណេះដឹងអំពីសេចក្តីស្រឡាញ់នេះ មានការផ្លាស់ប្តូរ និងឈានដល់កំរិតកាន់តែខ្ពស់ នៅពេលដែលយើងបានពិសោធន៍នឹងក្តីស្រឡាញ់ដោយខ្លួនឯង ដោយស្រឡាញ់អ្នកដទៃជាដើម។*

**ការសង្កេត** គឺជាការប្រើការគិត ដើម្បីរកបានចំណេះដឹង។ វាតម្រូវឲ្យយើងវិភាគទ្រឹស្តី និងធ្វើការបកស្រាយ ដើម្បីឲ្យយើងអាចពន្យល់ អំពីការសង្កេតរបស់យើង។ ឧទាហរណ៍ តាមការសង្កេត គេក៏បានសន្និដ្ឋានថា ទំនាញផែនដីបានការពារយើង មិនឲ្យអណ្តែត ឬហោះឡើងទៅលើមេឃ និងទីអវកាស ហើយការសង្កេតក៏បានជួយឲ្យគេដឹងថា វត្ថុដែលកាន់តែនៅជិតគ្នា ក៏ទាញចូលគ្នាកាន់តែខ្លាំង។ ការសង្កេតក៏បានធ្វើពិសោធមកលើអ្វីដែលយើងសង្ស័យថាត្រូវ ដោយផ្អែកលើសភាវគតិ ហើយក៏បានជួយយើងឲ្យទទួលបាននូវចំណេះដឹង ដើម្បីឲ្យយើងអាចសន្និដ្ឋាន អំពីសេចក្តីពិត ឲ្យកាន់តែច្បាស់លាស់។ វានាំឲ្យមានចំណេះដឹង ដែលច្បាស់លាស់ជាងសភាវគតិ។

**បទពិសោធន៍**ផ្តល់ឲ្យយើងនូវចំណេះដឹង អំពីអ្វីមួយដែលយើងបានជួប ឬឆ្លងកាត់ ដែលមិនគ្រាន់តែផ្តល់ឲ្យយើងនូវពត៌មានប៉ុណ្ណោះទេ។ យើងរាល់គ្នាសុទ្ធតែ

មានសភាវគតិ ដែលចេះស្រឡាញ់ ហើយយើងក៏អាចសង្កេតមើលអ្នកដែលកំពុងតែមានទំនាក់ទំនងស្នេហា។ ចំណេះដឹងអំពីសេចក្តីស្រឡាញ់នេះ មានការផ្លាស់ប្តូរនិងឈានដល់កំរិតកាន់តែខ្ពស់ នៅពេលដែលយើងបានពិសោធន៍នឹងក្តីស្រឡាញ់ដោយខ្លួនឯង ដោយស្រឡាញ់អ្នកដទៃជាដើម។ ហើយយើងក៏នឹងឲ្យតម្លៃចំពោះលក្ខណៈផ្សេងៗ និងសម្រស់នៃសេចក្តីស្រឡាញ់ ផ្អែកទៅលើបទពិសោធន៍របស់យើង។

គ្មានការសង្កេត ឬសភាវគតិណា ដែលអាចផ្តល់ឲ្យយើងនូវការយល់ដឹងច្រើនដូចបទពិសោធន៍នោះឡើយ។ ការនេះមិនមានន័យថា យើងគួរតែឲ្យតម្លៃទៅលើបទពិសោធន៍ខ្លាំងជាងការសង្កេត និងសភាវគតិនោះឡើយ តែវាគ្រាន់តែមានន័យថា បទពិសោធន៍ជាផ្នែកដ៏សំខាន់មួយទៀត ដែលជួយឲ្យយើងស្គាល់អ្វីមួយ។

**ប្រវត្តិសាស្ត្រ**ផ្តល់ឲ្យយើងនូវចំណេះដឹង តាមការសង្កេត ប៉ុន្តែ ខុសពីចំណេះដឹង ដែលយើងទទួលបានពីវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រមានជំនាញ នៅក្នុងការដឹងអំពីអ្វីមួយ តាមរយៈការធ្វើតេស្ត ម្តងហើយម្តងទៀត ដើម្បីធ្វើការសន្និដ្ឋាន ប៉ុន្តែប្រវត្តិសាស្ត្រផ្តល់ឲ្យយើងនូវចំណេះដឹង ដែល “មិនអាចធ្វើតេស្តម្តងហើយម្តងទៀត” បានឡើយ។ ឧទាហរណ៍ : តើធ្វើដូចម្តេចឲ្យយើងដឹងថា ស្តេចសេសាពិតជាមានមែន? ធ្វើដូចម្តេចឲ្យយើងដឹងថា អារ្យធម៌បុរាណរបស់ប្រទេសឥណ្ឌាបានកសាងអ្វីខ្លះ? យើងអាចដឹងបានតាមរយៈការសិក្សាប្រវត្តិសាស្ត្រ ដែលបានបើកវាំងននៃពេលវេលា ដើម្បីឲ្យយើងអាចដឹងថា មានអ្វីខ្លះកើតឡើង កាលពីអតីតកាល។

ទីបំផុត **ការបើកបង្ហាញ** ជួយឲ្យយើងស្គាល់មនុស្ស(គឺខុសពីទ្រឹស្តី ឬហេតុការណ៍)។ អ្នកទាំងនេះត្រូវតែចូលរួម នៅក្នុងដំណើរនៃការស្វែងរកចំណេះដឹង



*ពេលណាយើងចង់ដឹងការពិត អំពីនរណាម្នាក់ ការបើកបង្ហាញគឺជាប្រភពដំបូង នៃពត៌មានដែលយើងចង់ដឹង។*

របស់យើង ដោយពួកគេចាំបាច់ត្រូវប្រាប់យើង អំពីខ្លួនពួកគេ ឬអ្នកដទៃដែលស្គាល់ពួកគេ ត្រូវតែប្រាប់យើងអំពីពួកគេ។ ប្រវត្តិសាស្រ្តអាចប្រាប់យើង អំពីការអ្វីដែលអ៊ីត្លែបានធ្វើ ហើយតាមសភាវគតិ និងបទពិសោធន៍របស់យើង យើងអាចសន្និដ្ឋានថា គាត់ជាមនុស្សអាក្រក់។ ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចដឹងច្បាស់ថា អ៊ីត្លែជាមនុស្សបែបណាពិតប្រាកដឡើយ បើសិនជាគាត់មិនបានបើកបង្ហាញការពិតដោយខ្លួនឯងទេនោះ។

បើយើងមិនបានឮពីអ្នកដែលបានស្គាល់គាត់ដោយផ្ទាល់ខ្លួនទេ នោះយើងមិនមានការពិបាកវែកញែកការពិត អំពីខ្លួនគាត់ ចេញពីការអ្វីដែលគេប្រឌិតអំពីគាត់។ ពេលណាយើងចង់ដឹងការពិត អំពីនរណាម្នាក់ ការបើកបង្ហាញគឺជាប្រភពដំបូង នៃពត៌មានដែលយើងចង់ដឹង។

បន្ទាប់ពីយើងបានដឹងហើយថា ផ្លូវទាំង៥នេះ អាចជួយយើងស្វែងរកសេចក្ដីពិត នោះជាបន្តទៀតនេះ យើងអាចសួរថា : តើផ្លូវទាំង៥នេះអាចប្រាប់យើងអ្វីខ្លះ អំពីព្រះ?



*ទី៧*

## តើយើងអាចរកឃើញព្រះ ដោយរបៀបណា?

**យើងឃើញថា ការជឿថា** សាសនាទាំងអស់សុទ្ធតែត្រូវដូចគ្នា គឺជាការមើលរំលងភាពខុសគ្នារបស់សាសនាទាំងនោះ។ ដូចនេះ តើធ្វើដូចម្តេច ឲ្យយើងអាចដឹងសេចក្តីពិតថា ព្រះទ្រង់ជានរណា? យើងអាចគិតចង់ប្រើសភាវគតិ ការសង្កេត បទពិសោធន៍ ប្រវត្តិសាស្ត្រ និងការបើកបង្ហាញ ដើម្បីសួរនូវសំណួរដ៏សមហេតុផល នៅក្នុងការស្វែងរកចម្លើយដ៏ត្រឹមត្រូវ អំពីព្រះ?

បើព្រះជាម្ចាស់គ្រាន់តែជាអ្វីដែលមានក្នុងក្តីស្រមៃរបស់មនុស្ស នោះមនុស្សគ្រាន់តែប្រើសភាវគតិ ដើម្បីស្វែងយល់ពីទ្រង់ គឺគ្រប់គ្រាន់ហើយ។ បើព្រះជាម្ចាស់ជាប្រភេទនៃថាមពល ឬកម្លាំង នោះមនុស្សអាចប្រើតែបទពិសោធន៍ ដើម្បីស្វែងយល់ពីទ្រង់ គឺគ្រប់គ្រាន់។ ចុះបើសិនជាព្រះជាម្ចាស់ជាអង្គបុគ្គលវិញ? នោះយើងចាំបាច់ត្រូវប្រើការបើកបង្ហាញ។ បើសិនជាយើងចង់ស្វែងយល់អំពីព្រះដែលបានធ្វើការក្នុងប្រវត្តិសាស្ត្រ ហើយមានទំនក់ទំនងជាមួយមនុស្សជាតិ នោះផ្លូវផ្សេងៗគ្នា ដែលយើងអាចប្រើដើម្បីស្វែងរកចំណេះដឹង អាចបង្រៀនយើងអំពីព្រះជាម្ចាស់ តាមរបៀបផ្សេងគ្នា។ សភាវគតិ អាចជួយយើងឲ្យដឹងថា ព្រះពិត

ជាមានមែនឬអត់ ដោយមិនបាច់គិតច្រើន។ បទពិសោធន៍អាចជួយឲ្យយើងស្គាល់ព្រះវត្តមានរបស់ព្រះ។ ការសង្កេត និងប្រវត្តិសាស្ត្រនឹងជួយយើងឲ្យមើលឃើញលទ្ធផលនៃទំនាក់ទំនង រវាងព្រះជាម្ចាស់ និងមនុស្ស។ ហើយការបើកបង្ហាញនឹងជួយឲ្យយើងស្គាល់ព្រះ។



*ការសង្កេត និងប្រវត្តិសាស្ត្រនឹងជួយយើងឲ្យមើលឃើញលទ្ធផលនៃទំនាក់ទំនង រវាងព្រះជាម្ចាស់ និងមនុស្ស។*

កាលណាយើងសួរសំណួរទាំងនេះ អំពីលក្ខណៈរបស់ព្រះជាម្ចាស់ នោះយើងចាំបាច់ត្រូវចាំថា ចំណេះដឹងដែលយល់មួយរយភាគរយ គឺជាចំណេះដឹងដែលអាចទទួលយកបាន។ ក្នុងនាមយើងជាមនុស្ស សមត្ថភាពយើងមានកំណត់ ដូចនេះ យើងអាចដឹងច្បាស់អំពីអ្វីមួយ ក្នុងកំរិតខ្ពស់ អាចទទួលយកបាន។ ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចមានចំណេះដឹងអំពីអ្វីមួយឲ្យបានមួយរយភាគរយនោះឡើយ ជាពិសេស គឺចំណេះដឹងអំពីអង្គបុគ្គល ឬនរណាម្នាក់ ដែលរាប់បញ្ចូលទាំងខ្លួនយើងផងដែរ!

## តើហេតុអ្វីគ្រីស្ទបរិស័ទអះអាងថា ព្រះយេស៊ូវ ជាព្រះពិតតែមួយ?

ជាញឹកញាប់ ខ្ញុំច្រើនតែប្រាប់អ្នកដែលមានចំណាប់អារម្មណ៍ ចំពោះសេចក្តីពិត អំពីព្រះ ឲ្យចាប់ផ្តើមស្វែងយល់អំពីព្រះយេស៊ូវ។ មនុស្សជាច្រើនជឿថា ខ្ញុំនិយាយដូចនេះ គឺដោយសារខ្ញុំមានជំនឿបែបគ្រីស្ទបរិស័ទ។ ខ្ញុំមិនអាចបដិសេធទស្សនៈបែបគ្រីស្ទបរិស័ទបានឡើយ ព្រោះខ្ញុំមានហេតុផលរបស់ខ្ញុំ ដែលផ្អែកទៅលើលក្ខណៈនៃសេចក្តីពិត និងការអះអាងរបស់ព្រះយេស៊ូវ។

ដូចដែលយើងបានដឹងហើយ សេចក្តីពិតមានតែមួយទេ ហើយមិនចេះខុសនោះឡើយ។ យើងក៏ដឹងដែរថា តាមក្បួនឡូហ្សិក ការអះអាងពីរផ្ទុយគ្នា ដែលនិយាយ

អំពីសេចក្តីពិត មិនអាចត្រូវទាំងពីរបានឡើយ។ ឧទាហរណ៍ 2 x 2 មិន = 5 ឡើយ ហើយក៏មិន =3 ដែរ ព្រោះក្នុងករណីនេះ មានតែលេខ៤ទេ ដែលជាចម្លើយត្រូវតែមួយប៉ុណ្ណោះ។

បើយើងប្រើច្បាប់ឡូហ្សិកនេះមកពិនិត្យការអះអាង អំពីសេចក្តីពិត ក្នុងសាសនាផ្សេងៗ នោះយើងអាចធ្វើការសន្និដ្ឋានថា សាសនាទាំងអស់មិនអាចត្រូវទាំងអស់គ្នាឡើយ តែពួកគេអាចខុសទាំងអស់គ្នា។ ដូចនេះ តើហេតុអ្វីបានជាខ្ញុំនិយាយថា អ្នកដែលចូលចិត្តស្វែងរកសេចក្តីពិតអំពីព្រះ គួរតែចាប់ផ្តើមស្វែងយល់ អំពីព្រះយេស៊ូវ? មូលហេតុគឺដោយសារ ការអះអាងរបស់ព្រះយេស៊ូវ មានភាពងាយស្រួលនឹងឲ្យគេយកមកបកស្រាយថា ព្រះអង្គជាព្រះពិតមែន។

យើងប្រហែលជាមានការភ្ញាក់ផ្អើល ពេលដែលបានដឹងថា មានតែព្រះយេស៊ូវទេ ដែលបានអះអាងដោយខ្លួនឯងផ្ទាល់ថា ព្រះអង្គគឺជាព្រះ។ យើងអាចប្រើការអះអាងនេះ ជាឱកាស ដើម្បីបង្ហាញថា ព្រះអង្គពិតជាមានបន្ទូលខុសឬទេ។ យើងត្រូវដឹងថា សាសនានីមួយៗរំពឹងឲ្យសាសនិករបស់ខ្លួន ទទួលស្គាល់ថា ការអះអាងរបស់ខ្លួន មានភាពត្រឹមត្រូវ ដោយមិនមានភស្តុតាងដែលអាចមើលឃើញនោះឡើយ។ ឧទាហរណ៍ សាសនាហិណ្ឌូ បានបង្រៀនអំពីស្ថានមុគធិ (Mukthi) ដែលគ្មានដែនកំណត់ និងមិនមានលក្ខណៈជាអង្គបុគ្គល។ សាសនាព្រះពុទ្ធបានបង្រៀនអំពីនិព្វាន ដែលជាការត្រាស់ដឹង រួចចាកផុតអាត្មាខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ គេមិនអាចធ្វើតេស្ត មកលើការអះអាងរបស់សាសនាទាំងពីរឡើយ ព្រោះគ្មាននរណាម្នាក់ដែលអាចមើលឃើញស្ថានទាំងនេះឡើយ ព្រោះតាមការបង្រៀនរបស់សាសនាទាំងនេះ គេត្រូវស្លាប់ជាមុនសិន ដើម្បីឲ្យបានទៅដល់ស្ថាននោះ។ បើគ្មាននរណាម្នាក់ដែលបានស្លាប់ ហើយទៅដល់ស្ថាន

ទាំងនោះ ហើយត្រឡប់មកប្រាប់យើង ដោយមានភស្តុតាងដែលអាចមើលឃើញ អាចទទួលយកបានទេ តើធ្វើដូចម្តេច ឲ្យយើងដឹងថា ស្ថានទាំងនោះពិតជាមានមែន។

យ៉ាងណាមិញ ដើម្បីស៊ើបអង្កេតមើលសេចក្តីពិត ដែលព្រះយេស៊ូវបានអះអាង យើងមិនចាំបាច់ត្រូវស្លាប់ ហើយវិលត្រឡប់ពីការស្លាប់ ដើម្បីប្រាប់ការពិតនេះទេ តែវាផ្អែកទៅលើការសុគត និងមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។ ហេតុនេះហើយ រឿងនេះងាយនឹងឲ្យយើងបដិសេធបំផុត បើសិនជាវាមិនមែនជាការពិត។

ព្រះយេស៊ូវបានបញ្ជាក់ច្បាស់ថា ព្រះអង្គនឹងសុគត ហើយនៅថ្ងៃទី៣ ព្រះអង្គនឹងមានព្រះជន្មរស់ឡើងវិញ(ម៉ាកុស ៩:៣១)។ នេះជាការអះអាង ដែលបានធ្វើឲ្យសិស្សព្រះអង្គមានការភាន់ភាំង ហើយបន្ទាប់មក ការអះអាងនេះក៏បានធ្វើឲ្យពួកគេចេញទៅប្រកាស់ព្រះបន្ទូលព្រះអង្គ ដោយទំនុកចិត្ត។

គេអាចធ្វើការស៊ើបអង្កេត អំពីព្រះយេស៊ូវបាន ទោះគេមិនមែនជាគ្រីស្ទបរិស័ទក៏ដោយ ហើយអ្វីដែលគេត្រូវធ្វើ គឺត្រូវពិនិត្យមើលប្រវត្តិសាស្ត្រ ដោយចិត្តស្មោះត្រង់។

## ហេតុអ្វីបានជាប្រវត្តិសាស្ត្របានកត់ទុក អំពីព្រះយេស៊ូវ?

សូមយើងពិចារណា អំពីអ្វីដែលលោកបណ្ឌិត ចេម អាឡិន ហ្វ្រែនស៊ីស (Dr. James Allen Francis) បានមានប្រសាសន៍អំពីព្រះយេស៊ូវ នៅក្នុងការអធិប្បាយមួយ កាលពីឆ្នាំ១៩២៦ថា :

*មានទារកតូចមួយបានចាប់កំណើត ក្នុងភូមិមួយ ដែលមិនមានឈ្មោះល្បី។ ទ្រង់ក៏បានទទួលការចិញ្ចឹមបីបាច់ នៅក្នុងភូមិមួយទៀត ដែលគេមិនសូវស្គាល់។ ទ្រង់ធ្វើការជាជាងឈើ ទាល់តែទ្រង់មានព្រះជន្ម ៣០ឆ្នាំ ហើយ*

បន្ទាប់មក ទ្រង់ក៏បានដើរបង្រៀនព្រះបន្ទូលព្រះ ពីកន្លែងមួយទៅកន្លែងមួយ អស់រយៈពេល៣ឆ្នាំ។ ទ្រង់មិនដែលបាននិពន្ធសៀវភៅ មិនដែលមានការិយាល័យ មិនដែលមានកងទ័ព មិនដែលបានរៀបការ មិនដែលមានផ្ទះផ្ទាល់ខ្លួន មិនដែលទៅរៀននៅមហាវិទ្យាល័យ មិនដែលធ្វើដំណើរចម្ងាយ៣០០គីឡូម៉ែត្រ ពីស្រុកកំណើត។ ទ្រង់ប្រមូលបានមិត្តសំឡាញ់មួយក្រុមតូច ឲ្យដើរតាមទ្រង់ ហើយបានបង្រៀនពួកគេ ឲ្យដើរតាមផ្លូវរបស់ទ្រង់។

ដោយសារប្រជាប្រិយភាពរបស់ទ្រង់ មនុស្សជាច្រើនបានទាស់ប្រឆាំងនឹងទ្រង់។ មានមិត្តសំឡាញ់ម្នាក់បដិសេធទ្រង់ ហើយម្នាក់ទៀតក្បត់ទ្រង់។ គេបានបញ្ជូនទ្រង់ឲ្យទៅក្នុងដៃរបស់សត្រូវទ្រង់។ ទ្រង់បានឆ្លងកាត់ការកាត់ក្ដីដែលពេញដោយការចំអកប្រមាថ។ ទ្រង់ត្រូវគេឆ្កាង ដោយដំព្រះហស្ត និងព្រះបាទទ្រង់នឹងដែកគោលជាប់ឈើឆ្កាង នៅចន្លោះចោរពីរនាក់ ហើយពេលទ្រង់សុគត គេក៏បានយកសពទ្រង់បញ្ចុះក្នុងផ្នូររបស់មិត្តសំឡាញ់ម្នាក់។

នេះវារឿងពិតរបស់ទ្រង់ កាលទ្រង់មានព្រះជន្មជាមនុស្ស នៅលើផែនដី។ ហើយព្រះអង្គក៏បានមានព្រះជន្មរស់ឡើងវិញ ដូចដែលព្រះអង្គបានអះអាង មុនពេលព្រះអង្គសុគត។

សព្វថ្ងៃនេះ យើងក្រឡេកមើលទៅសម័យ ២ពាន់ឆ្នាំមុន ហើយសួរថា តើព្រះអង្គបានបន្សល់ទុកដានអ្វីខ្លះ ក្នុងរយៈពេលជាច្រើនសតវត្សរ៍កន្លងមកនេះ? ពេលណាយើងព្យាយាមបូកសរុបឥទ្ធិពលរបស់ទ្រង់ យើងនឹងឃើញថា កងទ័ពរបស់នគរទាំងអស់ដែលបានធ្វើសឹកសង្គ្រាម សភាទាំងអស់ដែលបានប្រជុំគ្នា ក្សត្រទាំងអស់ដែលបានគ្រងរាជ គឺសុទ្ធតែមានឥទ្ធិពលមកលើមនុស្សជាតិ តែមិនអាចប្រៀបផ្ទឹមនឹងឥទ្ធិពលរបស់ព្រះយេស៊ូវតែមួយអង្គឯងនោះឡើយ។

ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ មានបុគ្គលតិចណាស់ ដែលមានអត្តសញ្ញាណ ដែលនាំឲ្យមានការជជែកដេញដោល ដូចព្រះយេស៊ូវ។ ការជជែកដេញដោលនេះ គឺដោយសារទ្រង់បានអះអាងថា ទ្រង់ជាព្រះ ដែលបាននាំឲ្យគេកាត់ទោសប្រហារជីវិតទ្រង់។

ដូចនេះ តើហេតុអ្វីប្រវត្តិសាស្ត្រមានការនឹកចាំ អំពីព្រះយេស៊ូវច្បាស់យ៉ាងនេះ?

គឺដោយសារទ្រង់បានមានព្រះជន្មរស់ឡើងវិញ បន្ទាប់ពីទ្រង់សុគតនៅលើឈើឆ្កាង ហើយត្រូវគេបញ្ចុះក្នុងផ្នូរបានបីថ្ងៃ។

ពេលដែលពួកសាវ័ករបស់ទ្រង់បានជួបព្រះអង្គ បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ ពួកគេក៏មានទំនុកចិត្ត នៅក្នុងការប្រកាស់ថា ព្រះអង្គគឺជាព្រះ គឺថែមទាំងប្រកាស់ ទៅដល់អ្នកដែលបានកាត់ទោសទ្រង់ប្រហារជីវិត។ បើទ្រង់មិនបានមានព្រះជន្មរស់ឡើងវិញ នោះពួកគេក៏គ្មានហេតុផលអ្វីដែលត្រូវចេញទៅប្រឈមមុខដាក់គ្រោះថ្នាក់ ដើម្បីប្រកាស់ឲ្យគេជឿទ្រង់នោះឡើយ។ ពួកគេជឿជាក់ថា ព្រះយេស៊ូវគឺជាក្តីសង្ឃឹមតែមួយសម្រាប់មនុស្សជាតិ បានជាពួកគេប្រកាស់អំពីជំនឿលើព្រះយេស៊ូវ ដោយគ្មានការខ្មាស់អៀន ហើយក៏បាននាំអ្នកដទៃឲ្យដើរតាមព្រះអង្គ មិនមែនដោយសារពួកគេគិតថា ព្រះអង្គជាមនុស្សល្អ ឬជាគ្រូប្រកបដោយប្រាជ្ញា តែដោយសារពួកគេជឿថា ព្រះអង្គជាព្រះដ៏ពិត។ លោកយ៉ូហាន ជាសាវ័ករបស់ព្រះអង្គ បានសរសេរអំពីព្រះអង្គថា “យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត”(យ៉ូហាន ១:១៤)។

ពួកសាវ័ករបស់ព្រះយេស៊ូវ ជឿថា ព្រះអង្គ “ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត”(យ៉ូហាន ១៤:៦)។ ពួកគេបានប្រកាសថា ដំណឹងល្អអំពីទ្រង់ គឺជា “ព្រះចេស្តានៃព្រះសំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ”(រ៉ូម ១:១៦)។



*នេះជាទីបន្ទាល់ នៃការអ្វីដែលព្រះយេស៊ូវបានធ្វើ (និងបន្តធ្វើ)សម្រាប់ពិភពលោក។*

ក្នុងប្រវត្តិសាស្ត្រពិភពលោក អស់រយៈពេលជាច្រើនសតវត្សរ៍កន្លងមកនេះ មនុស្សរាប់រយលាននាក់ នៅតាមជាតិសាសន៍ ភាសា ឬមានប្រវត្តិកាន់តាមសាសនាផ្សេងៗ បានក្លាយជាអ្នកដើរតាមព្រះយេស៊ូវ ព្រោះពួកគេជឿថា ព្រះអង្គគឺជាព្រះពិតតែមួយ។

ហើយពួកគេបានស្តាប់បង្គាប់តាមព្រះរាជបញ្ជារបស់ព្រះអង្គឲ្យស្រឡាញ់អ្នកដទៃ(យ៉ូហាន ១៣:៣៤-៣៥) ដោយស្រឡាញ់ និងយកចិត្តទុកដាក់ ចំពោះអ្នកដទៃ ដូចព្រះយេស៊ូវដែរ ដោយបង្កើតសាលារៀន មន្ទីរពេទ្យ សង់ផ្ទះ មណ្ឌលកុមារកំព្រា កម្មវិធីជួយអ្នកក្រ និងអង្គការមនុស្សធម៌ នៅទូទាំងពិភពលោក។ នេះជាទីបន្ទាល់ នៃការអ្វីដែលព្រះយេស៊ូវបានធ្វើ(និងបន្តធ្វើ)សម្រាប់ពិភពលោក។ តើមាននរណានឹកស្មានថា ជាងឈើម្នាក់បានប្រែក្លាយជាគ្រូអធិប្បាយដ៏ល្បីល្បាញ ចេញពីភូមិមួយដែលគេមិនសូវស្គាល់ កាលពីជាងពីរពាន់ឆ្នាំមុន ហើយបាននាំមកនូវការផ្លាស់ប្តូរ ក្នុងប្រវត្តិសាស្ត្រ ក្នុងកំរិតដ៏ធំធេងយ៉ាងនេះ?



*ទី៨*

# តើអ្នកសម្រេចចិត្តយ៉ាងណា?

**នៅក្នុងសៀវភៅនេះ** យើងបានធ្វើដំណើរឆ្លងកាត់ការសន្និដ្ឋានដ៏ពេញនិយម អំពីសេចក្ដីពិត និងសាសនា ហើយបានពិនិត្យមើលគោលការណ៍ និងបញ្ហានៃសេចក្ដីពិតដែលផ្ដេកផ្ដួលលើគំនិត ទស្សនៈ និងជំនឿរបស់មនុស្ស ហើយបានព្យាយាមស្វែងយល់យ៉ាងលំបាក អំពីទំនាក់ទំនងរវាងចំណេះដឹង និងទស្សនៈ។ ខ្ញុំសង្ឃឹមថា យើងមានការយល់ដឹងកាន់តែស៊ីជម្រៅ អំពីមូលហេតុដែលយើងមិនអាចបង្កើតសេចក្ដីពិត ដោយចិត្តឯងបាន ទោះយើងមានចេតនាល្អយ៉ាងណាក៏ដោយ។ តែយើងមានការទទួលខុសត្រូវ នៅក្នុងការស្វែងរកអ្វីដែលពិត ហើយយើងអាចរកឃើញសេចក្ដីពិតបាន ដោយចាប់ផ្ដើមស្វែងយល់អំពីអង្គព្រះយេស៊ូវ ព្រោះការអះអាងរបស់ទ្រង់ថា អង្គទ្រង់ជាព្រះ គឺងាយនឹងឲ្យយើងបដិសេធន៍បំផុត បើសិនជាយើងរកឃើញថា ការអះអាងនោះមិនមែនជាការពិត។

បើអ្នកធ្វើការសង្កេតមើលសេចក្ដីពិត ដែលមានក្នុងប្រវត្តិសាស្ត្រ និងការបើកបង្ហាញ ហើយបើកចិត្តចំហរទទួលយកជីវិតដែលព្រះយេស៊ូវបានប្រទាន តាម

ព្រះបន្ទូលសន្យា នោះអ្នកនឹងរកឃើញថា “អ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ”(១យ៉ូហាន ៥:១២)។

ព្រះយេស៊ូវបានអញ្ជើញអ្នក ឲ្យចូលមករកព្រះអង្គ(ម៉ាថាយ ១១:២៨)។ នេះជាការត្រាស់ហៅយើងម្នាក់ៗ ដែលកំពុងមានជីវិតរស់នៅក្នុងពិភពលោក ហើយចង់ស្គាល់ព្រះដែលគ្មានដើមកំណើត ហើយក៏គ្មានទីបញ្ចប់។ តើអ្នកនឹងចូលមករកព្រះយេស៊ូវទេ?